# ប្រវត្តិវិទ្យាថ្នាក់ទី១១

2.1.សម័យចតុមុខ(ស.វទី១៥)

១.មូលហេតុដែលព្រះបាទពញាយ៉ាតប្តូររាជធានីពីអង្គរមកទួលបាសននៅឆ្នាំ១៤៣១គឺដោយសារ :

- បង្ហាញពីលក្ខណៈយុទ្ធសាស្រ្ត
- បង្ហាញពីភាពឈ្លាសវៃរបស់ព្រះអង្គ
- ដើម្បីការពារខ្លួនពីសំណាក់សត្រូវសៀម
- ដើម្បីស្វែរកទីតាំងសេដ្ឋកិច្ចថ្មីសម្រាប់ស្ថាជីវភាពប្រជារាស្រ្ត។

២.ព្រះបាទពញាយ៉ាតសោយរាជ្យចំនួនពីរលើកគឺលើកទី១គឺ(១៤២១-១៤៣១)និងលើកទី២(១៤៣២-១៤៦៣)។

ព្រះអង្គមានអ្នកម្នាងបីអង្គនិងបុត្រាបីព្រះអង្គគឺ:

- នរាយណ៍រាជា ជាបុត្រាជាមួយអ្នកម្នាងទេវី
- ស្រីរាជា ជាបុត្រាជាមួយអ្នកម្នាងបុទុមកេសរ
- ធម្មរាជា ជាបុត្រាជាមួយអ្នកម្នាងស៊ីសាងាម(សៀម)

៣.ហេតុអ្វីបានជាប្រទេសកម្ពុជាបែងចែកជាបីអាណាចក្រនៅស.វទី១៥?

បានជាប្រទេសកម្ពុជាបែងចែកជាបីអាណាចក្រគឺ ដោយសារតែវិបត្តិរាជវង្ស។ឆ្នាំ១៤៧៥ព្រះបាទស្រីរាជាបានសម្រាចព្រះទ័យនិងវាយរំដោះខេត្តខាងលិចពីសៀមវិញដោយឲព្រះបាទធម្មរាជាមើលការខុសត្រូវក្នុងរាជធានីរឹងស្រីសុរិយោទ័យដឹកនាំទ័ពជញ្ជូនស្បៀងនិងអាវុធ។

ព្រះបាទស្រីសុរិយោទ័យនិងព្រះបាទធម្មរាជាមានគំនិតចង់ដណ្តើមរាជជាហេតុធ្វើឲប្រទេសកម្ពុជាពេលនោះបែងចែកជាបីអាណាចក្រគឺ :

- ➢ អាណាចក្រខាងជើងគ្រប់គ្រងដោយស្រីរាជាមានរាជធានីនៅកំពង់សៀមមានខេត្តសុរិន្ទ គោកខ័ណ្ឌ កំពង់សៀម ជើងព្រៃ គោកសេះ ស្ទឹងត្រង់ កំពង់ស្វាយ រលាប្អៀរ ពោធិ៍សាត់ និងនាងរង។
- ➢ អាណាចក្រខាងកើតគ្រប់គ្រងដោយស្រីសុរិយោទ័យមានរាជធានីនៅស្រីសឈរឆ្នាំ១៤៧៧មានខេត្តស្រីសឈរ សម្បូរ ត្បូងឃ្មុំដល់ខេត្តដូនណាយ។
- ➢ អាណាចក្រខាងត្បូងគ្រប់គ្រងដោយធម្មរាជាមានរាជធានីនៅចតុមុខអភិសេកគ្រងរាជ្យឆ្នាំ១៤៧៨មានខេត្តសំរោងទង ថ្លុង កំពងសោម ទ្រាំង បាសាក់ ព្រះត្រពាំង ក្រមួនសចាប់ពីកោះស្លាកែតរហូតដល់ពាមកញ្ជើរ។

៤.បានជាមានជម្លោះរវាងស្រីសុគន្ធបទជាមួយស្តេចកនដោយសារ :

- ព្រះបាទស្រីសុគន្ធបទពេញព្រះទ័យនិងនាងពៅរួចតែងតាំងនាងពៅធ្វើជាស្នំឯក
- ស្រីសុគន្ធបទតែងតាំងនាយកនប្អូនប្រុសនាងពៅធ្វើជាមហាតលិក
- ឆ្នាំ១៥០៩ស្រីសុគន្ធបទសុបិន្តឃើញនាគរាជដ៏ធំមកយាយីព្រះកាយព្រះអង្គហោរាទស្សន៍ទាយចំលើនាយកន
- ស្រីសុគន្ធបទបានរៀបចំគម្រោងសម្លាប់នាយកន
- នាយកនរត់រួចខ្លួនទៅកុហក់បណ្តាថៅហ្វាយខេត្តបែកខាងកើតឲជួយកែនទ័ពកំចាក់ចន្ទរាជាក្បត់ចង់ដណ្តើមរាជ។
- ព្រះបាទចន្ទរាជភ័យក៏នាំរាជវង្សានុវង្សភៀសព្រះកាយទៅក្រុងអយុធ្យា
- ឆ្នាំ១៥១២ព្រះបាទស្រីសុគន្ធបទត្រូវនាយកនធ្វើឃាត។

❖ ស្រីជេដ្ឋាស្តេចកន(១៥១២-១៥១៦)ទ្រង់មានស្នាព្រះហស្តដូចជា :

- ព្រះអង្គតែងតាំងនាម៉ឺនមន្ត្រី ថៅហ្វាយខេត្តឲឡើងបុណ្យសក្តិគ្រប់លំដាប់។
- បង្កើតប្រាកស្លឹងឲប្រជារាស្ត្រចាយគ្រប់គ្នាដើម្បីសម្រួលក្នុងវិស័យពាណិជ្ជកម្ម។

៥.ចម្បាំងរវាងស្រីជេដ្ឋានិងព្រះបាទចន្ទរាជា(១៥១៦-១៥២៥)

- ការធ្វើឃាតស្តេចសុគន្ធបទពីសំណាក់ស្តេចកន
- ព្រះបាទចន្ទរាជាប្រើល្បិចដាក់ស្តេចសៀមទៅទាក់ដំរីស
- ស្តេចសៀមចាញ់កលចន្ទរាជាដោយប្រគល់ឲចន្ទរាជានូវដំរីផ្ទាក់ចំនួន១០០ទាហាន៥០០០នាក់ស្បៀងអាហារនិងដាវអាផ្លារសឹក
- មកដល់ខេត្តបាត់ដំបងចន្ទរាជាប្រមូលទ័ពបាន៣០០០នាក់ខេត្តសៀមរាបប្រមូលបាន៨០០០នាក់ខេត្តពោធិ៍សាត់ប្រមូលបាន៣០០០នាក់បន្ថែមទៀត។

## 2.2.សម័យលង្វែក(ស.វទី១៦)

១.ព្រះបាទចន្ទរាជាសោយរាជ្យពីឆ្នាំ១៥១៦-១៥៦៦។

២.បន្ទាយលង្វែកសាកសងចាប់ពីឆ្នាំ១៥២៧-១៥២៩ (មានរយៈពេល៣ឆ្នាំ)។

៣.រៀបរាប់ពីយុទ្ធសាស្ត្របន្ទាយលង្វែកៈ

ស្ថានភាពបន្ទាយលង្វែកជាចំណុចយុទ្ធសាស្ត្រមានទន្លេ បឹង និងព្រៃឈើជារបាំង។បន្ទាយនេះមានរាងបួនជ្រុងបណ្តោយ៣Kmទទឹង២Kmកំពែងដីកម្ពស់១៥ហត្ថ(៧.៥m)ហ៊ុមព័ន្ធដោយគូទឹកនិងដាំដើមឫស្សីកម្រាស់២សិន(១សិន=៤០m)ព័ន្ធជុំវិញ។ក្នុងបន្ទាយលង្វែកមានវាំងស្តេច បន្ទាយទាហាន ផ្ទះស្រីស្នំ២២រោងដំរីរោងសេះ ប្រាសាទពីរ ជីកស្រះធំ៤គ្រប់ទិសហើយចិញ្ចឹមត្រីព្រួល រ៉ស់ ឆ្តោ ព្រោះនៅជាប់មាត់ទន្លេសាបសង់ឃ្លាំង១៥ខ្ទងសម្រាប់ដាក់ស្រូវអង្ករត្រីងៀត ត្រីឆ្អើរ ប្រហុក ផ្អក...។

បន្ទាយលង្វែកមានទ្វារធំ៤នៅទិសទាំង៤និងទ្វារតូច៤នៅចំជ្រុងនៃទិសតូចទាំង៤។មានសួនច្បារធំ២មានភូមិអ្នកស្រុក៤មានវត្ត៥...។

៤.ព្រះបាទចន្ទរាជាមានបុត្រពីរអង្គគឺៈ

- ព្រះបាទរាមាធិបតី
- ព្រះបាទបរមេន្ទរាជា។

៥.បានជាជនជាតិអឺរ៉ុបមិនអាចផ្សព្វផ្សាយសាសនាគ្រិស្តក្នុងប្រទេសកម្ពុជាបានមកពីប្រជារាស្ត្រខ្មែរបានគោរពសាសនាព្រះពុទ្ធយ៉ាងមុតមាំរួចទៅហើយ។

៦.ព្រះបាទបរមេន្ទរាជាមានបុត្របីអង្គគឺៈ

- ព្រះបាទសត្ថាទី១
- ព្រះបាទស្រីសុរិយោពណ៌
- ព្រះបាទពញាអន។

៧.បានជាសៀមបង្ខំចិត្តចងស្ពានមេត្រីជាមួយខ្មែរដោយសារនៅឆ្នាំ១៥៧៤សៀមត្រូវភូមានិងខ្មែរវាយលុកខ្លាំងពេក។

៨.បានជាមានជម្លោះរវាងលាវនិងខ្មែរដោយសារៈ

- ឆ្នាំ១៥៧២ស្ដេចលាវបបួលស្ដេចខ្មែរប្រជល់ដំរីភ្នាល់ដាក់នគរ
- ដំរីលាវកម្ពស់៨ហត្ថដំរីខ្មែរកម្ពស់៧ហត្ថតែដំរីខ្មែរជល់ឈ្នះដំរីលាវ
- ឆ្នាំ១៥៧៤ស្ដេចលាវខឹងក៏លើកទ័ពមកវាយខ្មែរតែត្រូវចាញ់ទ័ពខ្មែរ។

៩.មូលហេតុនៃការបែកបន្ទាយលង្វែកគឺបណ្ដាលមកពីៈ

- កត្តាព្រះរាជាៈសត្ថាទី១ឆោតល្ងង់ទៅជួយរំដោះក្រុងអយុធ្យារបស់សៀមពីការត្រួតត្រារបស់ភូមា។
- កត្តាសៀមៈសៀមរមិលគុណប្រើល្បិចបញ្ជូនសង្ឃមកយកការណ៍ក្នុងបន្ទាយលង្វែកនិងប្រើល្បិចបាច់ប្រាក់ដួងចូលគុម្ពឫស្សី។
- វិបត្តិផ្ទៃក្នុងៈរាជវង្សានុវង្ស នាម៉ឺនមន្ត្រីប្រជារាស្ត្រមិនពេញចិត្តព្រះបាទសត្ថាទី១ដែលតែងតាំងកូនអាយុ១១ឆ្នាំឲគ្រងរាជនិង៦ឆ្នាំជាមហាឧបរាជ។ដូចនេះទើបពួកគេបាត់បង់ស្មារតីប្រយុទ្ធ។
- កត្តាប្រជារាស្ត្រៈក្រីក្រឆោតល្ងង់ចង់បានប្រាក់ដួងនាំគ្នាកាប់ឆ្ការគុម្ពឫស្សីដែលជារបងការពារបន្ទាយដ៏រឹងមាំ
- កត្តាសាមគ្គីៈប្រទេសខ្មែរហាក់ដូចជាបាត់បង់សាមគ្គីភាពដូចជាសត្ថាទី១នាំកូនទាំងពីររត់ភៀសខ្លួនទៅប្រទេសលាវប្រជារាស្ត្រអស់ជំនឿ។

១០.ផលវិបាកនៃការបែកបន្ទាយលង្វែកៈបន្ទាយលង្វែកត្រូវបានសៀមវាយបែកនៅឆ្នាំ១៥៩៤ដែលធ្វើឲកម្ពុជាជួបនូវផលវិបាកជាច្រើនដូចជាៈ

- ប្រទេសជាតិអស់ឫទ្ធានុភាពធ្លាក់ជារដ្ឋទន់ខ្សោយនៅអាស៊ីអាគ្នេយ៍
- ខ្មែរបាត់បង់កេតនភណ្ឌជាតិ ក្បួន ច្បាប់ អ្នកប្រាជ្ញ បណ្ឌិត និងវប្បធម៌ត្រូវសៀមឆក់ប្លន់អស់
- ប្រទេសធ្លាក់ក្នុងភាពអនាធិបតេយ្យ គ្រោះទុរ្ភិក្សពេញប្រទេស
- ព្រះរាជវង្សានុវង្សប្រព្រឹត្តអំពើពាលាលែងមានឫទ្ធនុភាព
- ប្រជារាស្ត្រអស់ជំនឿលើព្រះរាជា
- ប្រទេសកម្ពុជាបាត់បង់ខេត្ត ចន្ទបុរី បស្ទឹមបុរី នគររាជសីមា បាត់ដំបង សៀមរាប ពោធិ៍សាត់។

2.3.សម័យឧដុង្គ(១៦២០-១៨៦៣) (២៤៣ឆ្នាំ)

១.បានជាព្រះបាទស្រីរិយោពណ៌ចងសម្ព័ន្ធមេត្រីជាមួយយួនមកពីយល់ថាទំនាក់ទំនងខ្មែរ-សៀមបចាប់តាំងពីសម័យបោះបង់ចោលទីក្រុងអង្គររហូតមកដល់ការបែកបាក់បន្ទាយលង្វែកសៀមតែងតែយកប្រៀបលើខ្មែរតាមរយៈធ្វើសង្គ្រាមនិងកាត់ទឹកដីភាគខាងលិចទើបស្រីសុរិយោពណ៌សម្រេចព្រះទ័យមកចងសម្ព័ន្ធមេត្រីជាមួយយួនវិញ។

- នយោបាយបោះបង់ទំនាក់ទំនងជាមួយសៀមមិនបានផ្តលផលចំណេញដល់ប្រទេសខ្មែរនៅសម័យនោះទេតែផ្ទុយទៅវិញធ្វើឲខ្មែរយើងធ្លាក់ទៅក្នុងវិបត្តិកាន់តែជ្រៅថែមទៀតដោយសារះ
- ស្ថិតក្រោមឥទ្ធិពលសៀមនិងយួន
- ឆ្នាំ១៦២៣ប្រទេសអាណ្ណាមបានខ្ចីដីខ្មែរមានខេត្តកំពង់ក្របីនិងព្រៃនគរដើម្បីដាក់ទ័ពយួនដើម្បីវាយចិន
- សុំសិទ្ធិកាន់កាប់កំពងផែព្រៃនគររយៈពេល៥ឆ្នាំនិងសង់វិញ
- ឆ្នាំ១៦២៣ដោយមិនឃើញខ្មែរលើកស្លួយសារអាករឲសៀមក៏លើកទ័ពមកវាយខ្មែរជាពីរផ្នែកតាមខេត្តបរិបូរណ៍និងបន្ទាយមាស។

២.បានជាមានជម្លោះរវាងព្រះឧទ័យជាមួយនឹងព្រះរាជសម្ភារឬពញាតូដោយសារៈកាលនៅជាគ្រហស្ថក្នុងព្រជន្ម២១ព្រះវស្សាព្រះរាជសម្ភារត្រូវបានព្រះបិតាផ្សំផ្គុំជាមួយនាងបុប្ផាវតីនិងប្រគលរាជ្យសម្បត្តិថ្វានៅពេលព្រះអង្គលាចាកសិក្ខាបទ។ប៉ុន្តែព្រះឧទ័យក៏ស្រឡាញ់ហើយយកនាងបុប្ផាវតីជាមហេសី។លុះលាចាកសិក្ខាបទភ្លើងស្នេហ៍រវាងក្សត្រទាំងពីរក៏ឆាបឆេះម្តងទៀត។ព្រះឧទ័យបញ្ជាឲទ័ពដេញតាមសម្លាប់ព្រះរាជសម្ភារហើយព្រះអង្គក៏សុគតនៅលើចុងត្នោតរួមទាំងទាហារព័រទុយហ្គាល់២នាក់ផងដែរ។

៣.ដើម្បីព្យាបាលវិបត្តិក្នុងសង្គមខ្មែរព្រះបាទអង្គឌួងបានអនុវត្តដូចតទៅះ

- កំណែទម្រង់សង្គមៈជំរុញការស្ថាហេដ្ឋារចនាសម្ព័ន្ធមានផ្លូវគមនាគមន៍កំពង់ផែកំពតជាដើម។ព្រះអង្គធ្វើកំណែទម្រង់ប្រព័ន្ធប្រពៃណីដែលទុកកូនបំណុលជាខ្ញុំដាច់ថ្លៃដែលបរិច្ចាកប្រាក់ផ្ទាល់ព្រះអង្គដើម្បីលោះកូនបំណុលទាំងអស់ឲមានសេរីភាពឡើងវិញ
- ព្រះអង្គជាព្រះរាជាស្លូតត្រង់និងជាពុទ្ធសាសនិកប្រកាន់យុតិធម៌។
- នៅក្នុងវិស័យសាសនាព្រះអង្គបាននាំនូវគម្ពីរព្រះត្រៃបិដកជាច្រើនក្បាលពីប្រទេសសៀម។
- ព្រះអង្គបង្កើតរូបិយបណ្ណ័សម្រាប់ប្រើប្រាស់។

- ផ្នែករដ្ឋបាលព្រះអង្គបង្កើតខេត្តចំនួន៥២ដែលនៅសម័យមុនមានតែ៤០ខេត្ត។
- វិស័យវប្បធម៌ បង្កើតសាលារៀនតាមវត្តឲព្រះសង្ឃជួយបង្រៀនកូនខ្មែរកសាងវត្តអារាមលើកទឹកចិត្តដល់អ្នកប្រាជ្ញ បណ្ឌិត កវី ដោយផ្តល់ជាប្រាក់និងមធ្យោបាយផ្សេងៗ។
- ព្រះអង្គជាសាស្រ្តចារ្យភាសាខ្មែរជាអ្នកនិពន្ធដ៏ល្បីល្បាញដូចជារឿងចំប៉ាថោង(១៨១០)រឿងកាកី(១៨១៥)ច្បាប់ស្រី(១៨៣៧)។
- វិស័យពន្ធដារ ឲគេទាររបបភាស៊ីផ្តល់លទ្ធភាពឲរដ្ឋរៀបចំថវិកាមួយដែលមានតុល្យភាព។
- ចំពោះនយោបាយក្រៅប្រទេសនៅឆ្នាំ១៨៥៤ព្រះអង្គបានផ្ញើសារលិខិតទៅថ្វាយព្រះចៅអធិរាជបារាំងណាប៉ូឡេអុងទី៣ដើម្បីសុំការការពារពីបារាំងពីសំណាក់ការឈ្លានពានរបស់សៀមនិងយួន។ប៉ុន្តែលទ្ធផលមិនបានសម្រេចនៅឆ្នាំ១៨៥៥កម្ពុជាបានទទួលចម្លើយឆ្លើយតបពីព្រះចៅណាប៉ូឡេអុងទី៣ដែលទទួលស្គាល់កម្ពុជាត្រឹមជាដៃគូពាណិជ្ជកម្មប៉ុណ្ណោះ។

## 2.4.អរិយធម៌ខ្មែរក្រោយសម័យអង្គរ

១.វិស័យនយោបាយ

ប្រទេសកម្ពុជា ជារាជាណាចក្រដែលគ្រប់គ្រងដោយស្តេចជាម្ចាស់ផែនដីដែលមានបុព្វសិទ្ធនិងអំណាចធំធេងក្នុងការតែងតាំងមន្រ្តីជាន់ខ្ពស់និងចៅហ្វាយខេត្តឬដកហូតតំណែងមន្រ្តីណាក៏បានព្រះអង្គមានសិទ្ធិជ្រើសតាំងរាជវង្សានុវង្សជាមន្រ្តីជាន់ខ្ពស់។

ការជ្រើសតាំងព្រះរាជាថ្មីត្រូវប្រព្រឹត្តទៅតាមប្រពៃណីពីបុរាណគឺយកតែបុត្រច្បងនៃអគ្គមហេសី។

២.វិស័យរដ្ឋបាល

ក្រោយសម័យអង្គរគេបានបែងចែករដ្ឋបាលជា៤តំបន់ទៅតាមទិសធំទាំង៤។តំបន់នីមួយៗដឹកនាំដោយមន្រ្តីធំម្នាក់។តំបន់នីមួយៗចែកចេញជាច្រើនស្រុក(ខេត្ត)ដែលទទួលខុសត្រូវដោយមន្រ្តីម្នាក់ជាចៅហ្វាស្រុកនឹងអមដោយមន្រ្តីមួយចំនួនដូចជារដ្ឋបាល យោធា និងតុលាការ។

៣.វិស័យកងទ័ព

កងទ័ពខ្មែរបែងចែកជា៤ប្រភេទគឺទ័ពថ្មើរជើង ជើងទឹក ទ័ពចំណែក(មេ)ទ័ពខ្មោច បិសាច។ការប្រើដំរីជាសត្វមានមាឌធំងាយស្រួលក្នុងការដឹកជញ្ជូន។ក្រៅពីដំរីខ្មែរយើងមានទ័ពរទេះពីរទៀតគឺរទេះសេះនិងរទេះគោ។ក្រៅពីនេះមានទ័ពទូកជាទ័ពជើងទឹកដែលដឹកនាំដោយមន្រ្តីម្នាក់មានងារជាឧកញ៉ាក្រឡាហោម។

ទាហានត្រូវចេះក្បាច់ប្រយុទ្ធដូចជា គុនដាវ គុនលំពែង ដំបង ក្បាច់ប្រដាល់បុរាណរបៀបបាញ់ធ្នូរបៀបប្រយុទ្ធលើរទេះលើខ្នងដំរីនិងរបៀបជិះសេះ។

៤.វិស័យសង្គម

នៅក្នុងសង្គមខ្មែរសម័យសក្តិភូមិគេចែកសង្គមខ្មែរជាច្រើនស្រទាប់ដូចខាងក្រោម

- មន្ត្រីៈជាស្រទាប់ទី១ដែលគេនិយមហៅថាពួកនាម៉ឺនឬថ្នាក់ដឹកនាំ។
- ប្រជារាស្ត្រៈជាពករដ្ឋភាគច្រើនជាកសិករប្រកបរបរធ្វើស្រែចំម្ការ។ពួកនេះត្រូវបង់ពន្ធដីជាប់កំណែន សង់បន្ទាយ ទីក្រុងឬជីកស្រះ។
- ពួកអ្នកងារទាំងអស់សុទ្ធតែជាទាសករដូចជា ពលកម្លោះមហាតនៅបម្រើព្រះរាជាដូចជាឃ្វាលដំរី ធ្វើស្រែ ចាំឃ្លាំង បុកអង្ករ។
- ពួកទាសករហៅថាខ្ញុំគឺជាអ្នកជំពាក់បំណុលគេដោយប្រគល់ខ្លួនឲម្ចាស់បំណុល។
- ទាសករម្យ៉ាងទៀតបានពីការទិញឬត្រូវគេចាប់យកមកលក់សម្រាប់មុខរបរពាណិជ្ជកម្មដូចជាពួកទាសករស្បែកខ្មៅនៅសហរដ្ឋអាមេរិកនៅសតវត្សទី១៨ជាដើម។

៤.វិស័យវប្បធម៌

ក.អក្សរៈនៅសម័យក្រោយអង្គរពិសេសក្នុងរជ្ជកាលព្រះបាទចន្ទរាជាបានបន្សល់ទុកនូវសិលាចារឹកចំនួន៤០ផ្ទាំងនៅប្រាសាទអង្គរវត្ត។នៅសម័យក្រោយមកទៀតគេឃើញមានអក្សរដែលចារលើសាស្ត្រស្លឹករឹតនិងក្រាំងអធិប្បាយពីក្បួនច្បាប់ផ្សេងៗ។

ខ.ជំនឿទំនៀមទម្លាប់ៈប្រជាជនខ្មែរគោរពសាសនាធំពីរចាប់តាំងពីសម័យអង្គររហូតដល់សព្វថ្ងៃគឺព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាដែលនាំមកពីឥណ្ឌាប៉ុន្តែនៅសម័យក្រោយអង្គរគេគោរពពុទ្ធសាសនាបែបហិនយាន។

ជំពូក១.មេរៀនទី១.ស្ថានភាពទ្វីបអឺរ៉ុបមុនW.W1

World War1៖1915-1918

World War2៖1939-1945

The Wldwar៖1945-1990

១.ការប្រណាំងប្រជែងរវាងខាងកម្លាំងនិងសេដ្ឋកិច្ច

- នៅចុងស.វទី១៩និងដើមស.វទី២០ទំនាក់ទំនងអន្តរជាតិកាត់តែរង្គោះរង្គើខ្លាំងឡើងៗ
- នៅទ្វីបអាស៊ីអ្នកដែលចង់មានតួនាទីគឺជប៉ុនបានធ្វើឲប៉ះទង្គិចដល់ផលប្រយោជន៍រុស្ស៊ី អង់គ្លេស អាល្លឺម៉ង់ បារាំង និងសហរដ្ឋអាមេរិក។
- ទំនាស់បានកើតឡើងចេញពីអាណាចក្រអូតូម៉ង់ដែលលាតសន្ធឹងលើទឹកដីយ៉ាងធំធេងនៃតំបន់ភូមិភាគខាងជើងអាហ្វ្រិក តំបន់មជ្ឈិមបូព៌ា តំបន់អឺរ៉ុប ប៉ែកអាគ្នេយ៍។
- ទំនាក់ទំនងអន្តជាតិត្រូវបានកំណត់ផ្សេងទៀតពីគ្នាអាស្រ័យទៅនឹងផលប្រយោជន៍អស់កំពូលមហាអំណាចចាស់និងកំពូលមហាអំណាចថ្មី។

២.ការប្រណាំងប្រជែងខាងអាណានិគមនិយម

សង្គ្រាមដណ្តើមដែនដីអាណានិគមមានដូចជាៈ

- សង្គ្រាមអាមេរិក-អេស្ប៉ាញៈបានផ្ទុះឡើងតាំងពីឆ្នាំ១៨៤៩មកម្លោះដែលកើតចេញពីសហរដ្ឋអាមេរិកបានធ្វើសំណើសុំទិញកោះគុយបាពីអេស្ប៉ាញក្នុងតម្លៃ១០០លានដុល្លា។តែអេស្ប៉ាញបានបដិសេធព្រោះមិនធ្លាប់មានប្រពៃណីលក់ប្រទេសអាណានិគម។ឆ្នាំ១៨៩៥មានការបះបោរពីប្រជាជនគុយបាប្រឆាំងនឹងអំណាចគ្រប់គ្រងរបស់អេស្ប៉ាញដែលនេះជាឱកាសល្អសម្រាប់សហរដ្ឋអាមេរិកលូកដៃជួយកោះគុយបាប្រឆាំងនឹងអេស្ប៉ាញហើយទីបំផុតគ្រប់គ្រងកោះគុយបាតែម្តង។
- សង្គ្រាមរវាងចក្រភពអង់គ្លេសនិងសាធារណរដ្ឋប៊ួរពីឆ្នាំ១៨៩៩ដល់១៩០២ គឺជាសង្គ្រាមមួយដែលស្ថិតនៅខាងត្បូងនៃទ្វីបអាហ្វ្រិក។ក្នុងសង្គ្រាមនេះអង់គ្លេសបានបញ្ជូលកងទ័ពចំនួន២៥០០០០នាក់ទៅប្រយុទ្ធនឹងកងទ័ពប៊ួរ(មានដើមកំណើតពីហូឡង់)។នៅក្នុងសង្គ្រាមនេះអង់គ្លេសបានប្រើប្រាសអាវុធទំនើបៗជាហេតុធ្វើឲកងទ័ពប៊ួរត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ។
- សង្គ្រាមរុស្ស៊ីជប៉ុន(1904-1905)គឺជាសង្គ្រាមបែងចែកតំបន់អាណានិគមនៅចុងបូព៌ា។នៅក្នុងសង្គ្រាមនេះអង់គ្លេសនិងសហរដ្ឋអាមេរិកស្ថិតក្នុងភាគីជប៉ុន។អង់គ្លេសនិងអាមេរិកបានខ្ចីដៃជប៉ុនដើម្បីធ្វើឲ្យរុស្ស៊ីចុះទន់ខ្សោយ។

នៅឆ្នាំ1910ជប៉ុនបានយកកូរ៉េដាក់ជាប្រទេសអាណានិគមរបស់ខ្លួន ហើយនៅថ្ងៃខាងមុខនឹងឈានទៅយកតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ទាំងអស់។

៣.ការបង្កើតបក្សសម្ព័ន្ធយោធា(ប្លុក)

នៅសតវត្សរ៍ទី២០ទ្វីបអឺរ៉ុបបានកើតឡើងបក្សសម្ព័ន្ធយោធាពីរសំខាន់គឺៈ

1. សម្ព័ន្ធភាពត្រីភាគីអ៊ីតាលី អាល្លឺម៉ង់ អូទ្រីស-ហុងគ្រី
2. និងសម្ព័ន្ធភាពត្រីភាគី បារាំង រុស្ស៊ី អង់គ្លេស។

សម្ព័ន្ធភាពត្រីភាគីអ៊ីតាលីអាល្លឺម៉ង់អូទ្រីសហុងគ្រីបានកើតឡើងបន្ទាប់ពីសង្គ្រាមបារាំងព្រុស(ឆ្នាំ១៨៧០-១៨៧១)។ចំណែកបក្សសម្ព័ន្ធភាពត្រីភាគី បារាំង រុស្ស៊ី អង់គ្លេសគឺកើតឡើងបន្ទាប់ពីបក្សសម្ព័ន្ធទីមួយបានលេចចេញជារូបរាង។ក្នុងការបង្កើតបក្សសម្ព័ន្ធនេះបារាំងបានមើលឃើញដោយការគំរាមកំហែងយ៉ាងខ្លាំងពិសេសនៅតំបន់អឺរ៉ុប។

មេរៀនទី៥.សង្គ្រាមលោកលើកទី1(1914-1918)និងការបង្កើតសង្គមប្រជាជាតិ

១.បុព្វហេតុនៃសង្គ្រាម

- នយោបាយអនុត្តរភាពនៃបណ្តាប្រទេសមហាអំណាច
- សង្គ្រាមរវាងសហរដ្ឋអាមេរិក-អេស្ប៉ាញ(១៨៩៥-១៨៩៨)

- សង្គ្រាមអង់គ្លេស-សាធារណរដ្ឋប៊ួរ(១៨៩៩-១៩០២)
- សង្គ្រាមរុស្ស៊ី-ជប៉ុន(១៩០៤-១៩០៥)
- វិបត្តិខែកក្កដាឆ្នាំ១៩១៤
- ថ្ងៃទី28ខែមិថុនាឆ្នាំ1914និស្សិតស៊ែប៊ីពីររូបគឺព្រីនស៊ីបនិងហ្គាប្រីលឡូវិចបានធ្វើឃាតរជ្ជទាយាទនៃចក្រភពអូទ្រីស-ហុងគ្រីនៅទីក្រុងសេរ៉ាសីវ៉ូ។
- ថ្ងៃទី០១សីហាឆ្នាំ១៩១៤អាល្លឺម៉ង់ប្រកាសសង្គ្រាមជាមួយនឹងរុស្ស៊ី
- ថ្ងៃទី០៣សីហាមួយ១៩១៤អាល្លឺម៉ង់ប្រកាសសង្គ្រាមជាមួយបារាំង
- ថ្ងៃទី០៤សីហាអង់គ្លេសប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់
- នៅលើសមរភូមិមានប្រទេសចំនួន38ចូលរួម។

២.ព្រឹត្តិការណ៍សំខាន់ៗនៃសង្គ្រាម

- ទិសដៅនៃការចូលរួមក្នុងសង្គ្រាម
- អាល្លឺម៉ង់ប្រយុទ្ធដើម្បីបញ្ចប់ការគ្រប់គ្រងរបស់អង់គ្លេសលើផ្ទៃសមុទ្រនិងធ្វើឲ្យអង់គ្លេសចុះទន់ខ្សោយ។
- អូទ្រីស-ហុងគ្រីមានទិសដៅឈ្លានពានស៊ែប៊ីនិងបង្កើតឥទ្ធិពលរបស់ខ្លួននៅឧបទ្វីបបាល់កង់។
- ប្រទេសតួកគី គឺចូលរួមក្នុងសង្គ្រាមខាងភាគីអាល្លឺម៉ង់នៅរដូវស្លឹកឈើជ្រុះឆ្នាំ១៩១៤ក្នុងបំណងឈ្លានពានតំបន់ភ្នំកូកាសនៃស្តេចត្សាររុស្ស៊ីនិងបង្កើតការគ្រប់គ្រងរបស់ខ្លួននៅឧបទ្វីបបាល់កង់។
- អង់គ្លេសប្រយុទ្ធដើម្បីថែរក្សាដែនដីអាណានិគមរបស់ខ្លួននិងអំណាចគ្រប់គ្រងរបស់ខ្លួនលើផ្ទៃសមុទ្រ។
- បារាំងប្រយុទ្ធក្នុងបំណងដណ្តើមអាល់សាសនិងឡូរ៉ែនមកវិញដែលបាត់បង់ក្នុងសង្គ្រាមបារាំង ព្រុស។
- រុស្ស៊ីប្រយុទ្ធមានទិសដៅថែរក្សាឥទ្ធិពលរបស់ខ្លួននៅឧបទ្វិបបាល់កង់គ្រប់គ្រងតំបន់ហ្គាលីស៊ី តំបន់ណ័រម៉ាន់គ្រប់គ្រងច្រកចេញពីសមុទ្រខ្មៅ។
- ជប៉ុនប្រកាសសង្គ្រាមនឹងអាល្លឺម៉ង់ថ្ងៃទី២៩សីហា១៩១៤មានទិសដៅចូលឈ្លានពានតំបន់ទឹកដីរបស់អាល្លឺម៉ង់ដែលជាប់កិច្ចព្រមព្រៀងជួលពីចិន។

➢ បានជាសង្គ្រាមផ្លេកបន្ទោរមិនបានសម្រេចពីព្រោះ

- ធនធានមនុស្សគ្រឿងឧបភោគបរិភោគប្រទេសសម្ព័ន្ធមានចំនួនច្រើនជាងអាល្លឺម៉ង់។
- អាល្លឺម៉ង់បានធ្វើសង្គ្រាមលើសមរភូមិពីរក្នុងពេលតែមួយ។

➢ បានជាសហរដ្ឋអាមេរិកចូលរួមក្នុងសង្គ្រាមលោកលើកទី១ពីព្រោះ

- ប្រញ៉ាប់ប្រញាល់ដើម្បីចូលរួមក្នុងការទទួលលាភសក្ការៈបានមកពីការបែងចែកពិភពលោកដំណាក់កាលក្រោយសង្គ្រាម។
- នាវាចម្បាំងអាល្លឺម៉ង់បានប្រកាសបិទមិនឲ្យនាវាគ្រប់ធុនចូលសុំចតកំពុងផែអឺរ៉ុបដែលជាតំបន់កំពុងផ្ទុះសង្គ្រាម។

➢ បានជារុស្ស៊ីដកខ្លួនចេញពីសង្គ្រាមដោយសារៈ

- ថ្ងៃទី០៧វិច្ឆិកាឆ្នាំ១៩១៧ពួកបុលសេវិចដឹកនាំដោយលេនីនបានដណ្តើមអំណាចពីរដ្ឋាភិបាលលោកកេរីនស្គី ដែលបានបង្កើតឡើងបន្ទាប់ពីអំណាចស្តេចត្សារក្នុងបដិវត្តន៍ខែកុម្ភៈឆ្នាំ១៩១៧។

➢ ផលវិបាកនៃសង្គ្រាមៈសង្គ្រាមលោកលើកទី1(១៩១៤-១៩១៨)ដែលមានប្រទេសចូលរួមចំនួន៣២បានផ្តល់នូវផលវិបាកដូចជាៈ

- បាត់បង់ជីវិតមនុស្ស១០លាននាក់និងរបួស២០លាននាក់
- បាត់បង់សម្ភារៈសន្និកសន្ទាប់និងប្រជាជនស៊ីវិលជាច្រើនលាននាក់
- សង្គ្រាមបានកម្ទេចអស់ហេដ្ឋារចនាសម្ព័ន្ធមានលំនៅឋានផ្លូវដែកស្ពានរោងចក្រទីក្រុង...។

➢ ដំណោះស្រាយក្រោយសង្គ្រាម

❖ សន្និសីទទីក្រុងវ៉ៃសៃ

សន្និសីទទីក្រុងវ៉ៃសៃត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៩មេសា១៩១៩ដែលមានទីស្នាក់ការនៅទីក្រុងប៉ារីសប្រទេសបារាំង។កិច្ចព្រមព្រៀងនេះមានខ្លឹមសារមួយចំនួនទាក់ទងទៅនឹងប្រទេសអាល្លឺម៉ង់មានដូចជាៈ

- អាល្លឺម៉ង់ត្រូវបោះបង់ដែនដីអាណានិគមរបស់ខ្លួន
- ហាមឃាត់អាល្លឺម៉ង់មិនឲ្យមាននាវាមុជទឹក នាវាចម្បាំងលើទឹកធំៗ កងទ័ពរថក្រោះ កងទ័ពអាកាសនិងកាំភ្លើងធ្លោងធុនធ្ងន់។
- សេនាធិការយោធាអាល្លឺម៉ង់ត្រូវរំសាយចោល
- កាតព្វកិច្ចនិងបរិច្ចាកកិច្ចយោធាត្រូវលុបបំបាត់ចោល
- កងទ័ពអាល្លឺម៉ង់ត្រូវមានចំនួនអតិបរិមាណ១០០៣ន់នាក់
- អាល្លឺម៉ង់ត្រូវសងរាលការខូចខាតគិតជាទំហំទឹកប្រាក់ស្មើនឹង១៣២៣ន់លានម៉ាករូបិយវត្ថុដែលអាល្លឺម៉ង់ត្រូវសង។

➢ អង្គការសង្គមប្រជាជាតិត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៩ មេសា ១៩១៩ ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។អង្គការបង្កើតក្នុងគោលបំណងថែរក្សាសន្តិភាពនិងស្ថេរភាពពិភពលោក។អ្នកដែលផ្តើមគំនិតបង្កើតអង្គការនេះគឺលោកវីល សុនប្រធានាធិបតីអាមេរិក។

## 1.9 ការបាត់បង់តុល្យភាពក្រោយ W.W1

១.ស្ថានភាពទូទៅនៃវិបត្តិ

មហាសង្គ្រាមលោកលើកទី1បានធ្វើឲពិភពលោកយើងទាំងមូលជាពិសេសទ្វីបអឺរ៉ុបធ្លាក់ក្នុងស្ថានភាពមួយប្រកកបដោយគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ។

២.វិបត្តិសេដ្ឋកិច្ច

ការបាត់តុល្យភាពនៃសេដ្ឋកិច្ចមានរូបភាពពិស្តារជាងវិស័យណាៗទាំងអស់។ក្រោយចម្បាំងមហាអំណាចអឺរ៉ុបត្រូវបាត់បង់ទីផ្សារនឹងឧស្សាហកម្មជាមូលដ្ឋានរបស់ខ្លួន។

ក្នុងពេលជាមួយគ្នានោះប្រទេសខ្លះបានពង្រឹងទីផ្សាររបស់ខ្លួនឡើងវិញដូចជាប្រទេសអាមេរិក ជប៉ុន កាណាដា អូស្រ្តាលី ប្រេស៊ីល។

៣.វិបត្តិរូបិយវត្ថុៈបាតុភាពដោយជាក់ស្តែងនៃការបាត់ តុល្យភាព សេដ្ឋកិច្ចគឺស្ថិតនៅលើ វិបត្តិរូបិយវត្ថុដែលគ្រប់ប្រទេសបានពើបប្រទះជាញឹកញាប់។ ក្នុងការឆ្លើយតប ត្រូវនឹងតម្រូវការចាំបាច់របស់រដ្ឋនីមួយៗ បានបោះក្រដាសប្រាក់បន្ថែមមានចំនួនច្រើនលើសលុបជាហេតុនាំឲ្យរូបិយវត្ថុទាំងនោះបាត់តម្លៃបណ្តាលឲ្យអ្នកទីទ័លក្ររឹតតែពិបាកឡើងៗ។

៤. វិបត្តិទីផ្សារសេរីៈផលិតករប្រមូលគ្នាជាក្រុមហ៊ុនមួយ ហើយបានកំណត់ចំនួនទំនិញដែលត្រូវផលិតយ៉ាងតឹងរ៉ឹងកម្រិតតម្លៃផលិតផល លើទីផ្សារជាក់លាក់និងកំណត់ទីផ្សារឲ្យច្បាស់លាស់។

៥.វិបត្តិនយោបាយនិងសង្គម

- វិបត្តិនយោបាយៈក្នុងវិស័យនយោបាយមហាសង្គ្រាមបានធ្វើឲ្យ សាបសូន្យរបបរាជានិយមជាច្រើននៅអឺរ៉ុបនិងជំនួសមកវិញនូវរបបសាធារណរដ្ឋ។
- ការបាត់តុល្យភាពខាងសង្គម មនុស្សជាច្រើនលាននាក់ត្រូវធ្លាក់ខ្លួនចុះក្នុងស្ថានភាពក្រីក្រលំបាកតោកយ៉ាក។ រងទុក្ខវេទនាដោយសារសង្គ្រាមផងដោយសារគ្មានការងារធ្វើផង។

នៅប្រទេសតណ្ហាប្រទេសចិននៅមជ្ឈឹមបូព៌ាប្រទេសស្រ្តីៗលែងរស់នៅតែរង្វងផ្ទះទៀតហើយ។

ស្រ្តីបានរំដោះខ្លួនរួចចេញពីស្ថានភាពទំនៀមទម្លាប់ប្រពៃណីដែលបានចងភ្ជាប់ជាច្រើនសតវត្សមក។

## 1.15.បញ្ហាសំខាន់មុនសង្គ្រាមលោកលើកទី2

១.បញ្ហាសំខាន់មុនសង្គ្រាមលោកលើកទី២មានដូចជា៖

- បញ្ហាអាល្លឺម៉ង
- បញ្ហានៅតំបន់អឺរ៉ុបកណ្តាលនិងបាល់កង់
- បញ្ហានៅតំបន់មជ្ឈឹមបូព៌ា
- បញ្ហានៅចុងបូព៌ា។

២. បញ្ហាសំខាន់ៗនៅតំបន់អឺរ៉ុបកណ្តាលមានដូចជា៖

- ក្រោយចម្បាំងចក្រភពអូទ្រីសហុងគ្រីផុតរលត់ហើយរដ្ឋថ្មីៗជាច្រើនបានចាប់កំណើតនៅតំបន់នោះ។
- អូទ្រីស_ហុងគ្រីត្រូវចែកចេញជាពីររដ្ឋគឺ រដ្ឋអូទ្រីសមួយនិងរដ្ឋហុងគ្រីមួយ ។
- ដោយយល់ពីគ្រោះថ្នាក់ចំពោះមុខប្រទេសឆេកូស្លូវ៉ាគី រូម៉ានីនិងយូហ្គោស្លាវីបានព្រមព្រៀងគ្នាធ្វើអនុសញ្ញាត្រីភាគីមួយដែលមានបារាំងជាអ្នកគាំទ្រ ។

- សន្ធិសញ្ញាបារាំង_ឆេកូស្លូវ៉ាគីឆ្នាំ១៩២៥ បារាំង_រូម៉ានីឆ្នាំ១៩២៦។
- នៅឆ្នាំ១៩២៧មានធ្វើកិច្ចចុះសន្ធិសញ្ញាបារាំងយូហ្គោស្លាវីក្នុងពេលជាមួយគ្នានោះប្រទេសអ៊ីតាលីនិងប្រទេសអាល្លឺម៉ង់បានគាំទ្រប្រទេសអូទ្រីសនិងប្រទេសហុងគ្រី ផងដែរ ។

៣.បញ្ហាសំខាន់ៗនៅតំបន់មជ្ឈឹមបូព៌ាមានដូចជាៈ

- ចលនាជាតិនិយមរបស់ប្រជាជនដែលត្រូវគេ ជិះជាន់ ប្រឆាំងនិងពួកអាណានិគមនិយម។
- ពួកមហាអំណាចបារាំងអង់គ្លេសបានធ្វើឲ្យស្ថានភាពនយោបាយកាន់តែតឹងតែង ខ្លាំងឡើង ដើម្បីពង្រឹងរងឥទ្ធិពលខ្លួន។
- នៅតួកគី គឺលោក មុំស្តាហ្វាកេម៉ាល់ដែលគេនិយមហៅថាកេម៉ាល់អាតាតួក បានធ្វើរដ្ឋប្រហារហើយប្រកាសរបស់សាធារណរដ្ឋនិយមនៅតួកគី។
- តួកគីបានដណ្តើមយកមកវិញនូវតំបន់ទាំងឡាយដែល សន្ធិសញ្ញាក្រុងសែវបានផ្តល់ទៅឲ្យប្រទេសដ៏ទៃដូចជាក្រុងស្មៀក តំបន់អាណាតូលី អង់ឌ្រីណូបនិងត្រាសជាដើម ។
- ប្រទេសលីបង់និងស៊ីរីត្រូវធ្លាក់ក្រោមកិច្ចត្រួតត្រារបស់បារាំង ឆ្នាំ១៩២០។

៤.បញ្ហាសំខាន់នៅតំបន់ចុងបូព៌ាមានដូចជាៈ

- ប្រទេសអាល្លឺម៉ង់ចាប់ផ្តើមបាត់បង់ទឹកដីគ្រប់គ្រងរបស់ខ្លួននៅប្រទេសចិន។
- ជប៉ុនបានវាយដណ្តើមយកទឹកដីចិនជាច្រើនក្នុងពេលជាង សង្គ្រាមចក្រព័ន្ធនិយមជាហេតុបណ្តាលឲ្យអង់គ្លេសបារាំងពិសេសសហរដ្ឋអាមេរិកពុំសប្បាយចិត្តឡើយ។
- សន្ធិសញ្ញាទីក្រុងវ៉ាស៊ីនតោនដែលមានអាមេរិកអ្នកផ្តួចផ្តើមគំនិតបានតម្រូវឲ្យជប៉ុនប្រគល់តំបន់ដូចជាខេត្តសានតុងដែលគេដណ្តើមយកពីអាល្លឺម៉ង់ក្នុងសង្គ្រាមជាដើម។

៥.ស្ថានភាពពិភពលោកពីឆ្នាំ(១៩២៩-១៩៣៩)

- នៅឆ្នាំ១៩៣១ មហាវិបត្តិមួយបានផ្ទុះនៅចុងបូព៌ាពោលគឺប្រទេសជប៉ុនបានវាយលុកដណ្តើមយកអាណាខេត្តម៉ាន់ជូរីរបស់ចិន។ឆ្នាំ១៩៣៣ជប៉ុនដើរចេញពីសង្គមប្រជាជាតិ។
- ឆ្នាំ១៩៣១អាល្លឺម៉ង់ ឈប់បង់សំណង របស់ខ្លួនដល់មេបំណុលទាំងឡាយដោយសំអាងទៅលើវិបត្តិសេដ្ឋកិច្ច។
- ឆ្នាំ១៩៣២អ៊ីតាលីបានវាយដណ្តើមយកតំបន់រេណានីដែលទុកជាតំបន់គ្មានអាវុធតាមកិច្ចព្រមព្រៀងអន្តរជាតិ។
- ឆ្នាំ១៩៣៣អាល្លឺម៉ង់បានចាកចេញពីសន្និសីទរំលាយសព្វាវុធ។
- វិបត្តិនៅឆេកូស្លូវ៉ាគីៈសន្និសីទក្រិងមុយទិច(២៩កញ្ញា១៩៣៨)បានលក់ប្រទេសឆេកូស្លូវ៉ាគីឲទៅអ៊ីតាលីលើខ្នងប្រជារាស្ត្រ។
- សន្ធិសីទមិនឈ្លានពានគ្នាទៅវិញទៅមករវាងរុស្ស៊ីអាល្លឺម៉ង់ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៣សីហា១៩៣៩។
- ចំណុចខ្សោយរបស់បារាំងនិង អង់គ្លេសធ្វើឲ្យអ៊ីតាលីបញ្ជូនទ័ពទៅវាយលុកប្រទេសមកប៉ូឡូញនៅថ្ងៃ០១កញ្ញា១៩៣៩។

# 1.16.សង្គ្រាមលោកលើកទី2(1939-1945)

## ១.មូលហេតុនៃសង្គ្រាមលោកលើកទី២

### ១.១.សម្ព័ន្ធភាពប្រជាជាតិនិងប្រព័ន្ធម៉ាន់ដាន

- យន្តការដំណោះស្រាយទំនាស់នៅក្នុងទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមលោកលើកទី១ផ្តើមគំនិតដោយលោកវីលសុន។
- ស្ថាប័នកំពូលរបស់អង្គការមហាសន្និបាត ដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំ។
- លក្ខន្តិកៈនៃសម្ព័ន្ធភាពប្រជាជាតិបង្ហាញពីសេចក្តីសម្រេចចិត្តជាសមូហភាពក្នុងការដាក់ទាណ្ឌកម្មលើប្រទេសឈ្លានពានដោយមធ្យោបាយសេដ្ឋកិច្ចឬយោធា។
- ក្នុងនាមសម្ព័ន្ធភាពប្រជាជាតិអង់គ្លេសបានទទួលម៉ាន់ដាតលើទឹកដីប៉ាឡេស្ទីន ហ្សកដានី អ៊ីរ៉ាក់ តាន់ហ្គានីកា។បារាំងទទួលម៉ាន់ដានលើ ស៊ីរី លីបង់។ជប៉ុនទទួលម៉ាន់ដានលើកោះម៉ារីយ៉ាន ម៉ាសាល ការ៉ូលីន និងឧបទ្វីបសានទុង។

➢ នយោបាយសង្គ្រាមឈ្លានពានរបស់អ៊ីតាលី អាល្លឺម៉ង់និងជប៉ុន

- នយោបាយវាតទីរបស់បក្សណាស៊ីអាល្លឺម៉ង់ ៖

ដំណាក់ការពីឆ្នាំ(១៩៣៣-១៩៣៥)បន្ទាប់ពីអ៊ីត្លែឡើងកាន់អំណាចមកទិសដៅសំខាន់របស់បក្សណាស៊ីគឺលុបចោលបម្រាមការផលិតសព្វាវុធរបស់អាល្លឺម៉ង់ដែលមានចែងក្នុងសន្ធិសញ្ញាវ៉ៃសៃ។បន្ទាប់មកនៅឆ្នាំ១៩៣៥អាល្លឺម៉ង់បានអនុម័តច្បាប់បរិច្ចាគកិច្ចយោធ បានផលិតសព្វាវុធនិងពង្រឹងទ័ពរបស់ខ្លួនឡើងវិញ។

- ការឈ្លានពានរបស់អ៊ីតាលីទៅលើអេត្យូពីនិងជ្រៀតជ្រែកនយោបាយអេស្ប៉ាញ៖

ដោយសំអាងទៅលើសិទ្ធគ្រប់គ្រងទៅលើប្រទេសអាណានិគមនៅឆ្នាំ១៩៣៥កងទ័ពអ៊ីតាលីបានវាយលុកប្រទេសអេត្យូពី។ពួកហ្វាស៊ីសបានបោះជំហានដំបូងរបស់ខ្លួនក្នុងការធ្វើសង្គ្រាមមហាអំណាចដោយចំហហើយទីបញ្ចប់អ៊ីតាលីក៏ទទួលបានជោគជ័យនៅឆ្នាំ១៩៣៩។

## ៣.ព្រឹត្តិការសំខាន់ៗនៃសង្គ្រាម

គេបែងចែកសង្គ្រាមលោកលើកទី២ជាពីរដំណាក់កាល

- ដំណាក់កាលទី១(១៩៣៩-១៩៤១)ដំណាក់កាលទី១ចាប់ផ្តើមពីថ្ងៃទី០១កញ្ញា១៩៣៩នៅពេលកងទ័ពអាល្លឺម៉ង់បានចូលឈ្លានពានប្រទេសប៉ូឡូញបារាំងនិងអង់គ្លេសភាគីជាប់កិច្ចព្រមព្រៀងជាមួយប៉ូឡូញក៏ប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់។បន្ទាប់មកកតិកាសញ្ញារ៉ូម ប៊ែរឡាំង តូក្យូបានប្រកាសសង្គ្រាមផងដែរ។
- ដំណាក់កាលទី២(១៩៤១-១៩៤៥)ដំណាក់កាលនេះចាប់ផ្តើមនៅពេលដែលកងទ័ពអាល្លឺម៉ង់រួមជាមួយទ័ពសម្ព័ន្ធមិត្តរបស់ខ្លួនបានរំលោភលើសន្ធិសញ្ញាមិនឈ្លានពានគ្នារវាងអាល្លឺម៉ង់ សូវៀតផ្ទុយទៅវិញអាល្លឺម៉ង់រំលោភចូលទឹកដីសូវៀតថ្ងៃទី២២មិថុនា១៩៤១។
- ថ្ងៃទី០៩ឧសភា១៩៤៥អាល្លឺម៉ង់បានប្រកាសទម្លាក់អាវុធសុំចុះចាញ់
- ថ្ងៃទី១៥សីហា១៩៤៥ជប៉ុនបានទម្លាក់អាវុធសុំចុះចាញ់ផងដែរ។សង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់។

- ➢ សមាសភាពចូលរួមក្នុងសង្គ្រាម
  ក្នុងសង្គ្រាមលោកលើកទី២គេបែងចែកកម្លាំងដែលចូលរួមជាពីរក្រុមគឺ
- កម្លាំងមហាអំណាចឈ្លានពានឬអំណាចកណ្តាលមានដូចជាប្រទេសអាល្លឺម៉ង់ អ៊ីតាលី ជប៉ុន រួមជាមួយនឹងប្រទេសតូចៗមួយចំនួនដែលស្ថិតក្រោមឥទ្ធិពលរបស់គេ។
- កម្លាំងសម្ព័ន្ធមិត្តមានដូចជាសហភាពសូវៀត សហរដ្ឋអាមេរិក ចក្រភពអង់គ្លេសនិងសម្ព័ន្ធមិត្តរបស់គេ។

៤.ផលវិបាកនៃសង្គ្រាមលោកលើកទី២

- សង្គ្រាមលោកលើកទី២បានអូសប្រទេសចំនួន៧២៩ចូលរួមនិងមនុស្សប្រមាណ៦២លាននាក់។
- ខូចខាតសម្ភារៈច្រើនឥតគណនាទីក្រុងជាច្រើនក្លាយទៅជាផេះ
- បំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សាលារៀន
- បំផ្លាញជីវិតមនុស្សចំនួន៤៥លាននាក់និងជនពិការជាច្រើនលាននាក់។

ចប់

✍ ប្រទេសកម្ពុជាឆ្លងកាត់សម័យ១៥ដំណាក់កាលៈ

1. សម័យហ្វូណនឬនគរភ្នំ ស.វទី១ដល់ឆ្នាំ៥៥០
2. សម័យចេនឡា ស.វទី៦ដល់ឆ្នាំ៨០២
3. សម័យអង្គរ ឆ្នាំ៨០២ដល់ឆ្នាំ១៤៣១
4. សម័យចតុមុខ ឆ្នាំ១៤៣១ដល់ឆ្នាំ១៥១៦
5. សម័យលង្វែក ឆ្នាំ១៥១៦ដល់ឆ្នាំ១៦២០
6. សម័យឧត្តុង្គ ឆ្នាំ១៦២០ដល់ឆ្នាំ១៨៦៣
7. សម័យអាណានិគមនិយមបារាំង ឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ (៩០ឆ្នាំ)
8. សម័យអាណានិគមជប៉ុន ឆ្នាំ១៩៤១ដល់ឆ្នាំ១៩៤៥
9. សម័យសង្គមរាស្ត្រនិយម ឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៧០
10. សម័យសាធារណៈរដ្ឋខ្មែរ(លន់ នល់)ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥
11. សម័យកម្ពុជាប្រជាធិបតេយ្យ(ប៉ុល ពត)ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩(៣ឆ្នាំ៨ខែ២០ថ្ងៃ)
12. សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩
13. សម័យរដ្ឋកម្ពុជា ឆ្នាំ១៩៨៩ដល់ឆ្នាំ១៩៩៣
14. សម័យអ៊ុនតាក់(អង្គការសហប្រជាជាតិ)ឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៣
15. សម័យព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ដល់ឆ្នាំបច្ចុប្បន្ន។

ប្រទេសកម្ពុជាមានផ្ទៃដី១៨១ ០៣៥$Km^2$ , មានរាជធានី១គឺរាជធានីភ្នំពេញ

កិច្ចព្រមព្រៀងទីក្រុងប៉ារីស២៣ តុលា ១៩៩១ , កម្ពុជាចូលជាសមាជិកអាស៊ាន ៣០ មេសា ១៩៩៩

កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ ១៤ ធ្នូ ១៩៥៥ , កម្ពុជាទទួលបានឯករាជ្យពីបារាំង ៩ វិច្ឆិកា ១៩៥៣

✍ ព្រឹត្តិការណ៍សំខាន់ៗនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា

- ថ្ងៃ ១៩ មេសា ១៩៥៣៖ កាសែតញូយ៉កថែម បានចុះផ្សាយ នៅលើទំព័រមុខរបស់ខ្លួននូវអត្ថបទដែលមានឥទ្ធិពលដូចគ្រាប់បែកមួយគ្រាប់។
- ថ្ងៃ ២៣ មេសា ១៩៥៣៖ អាមេរិកបានជំរុញឲ្យបារាំងទទួលយកការចរចាជាមួយខ្មែរនាទីក្រុងប៉ារីស ដែលមានឯកឧត្តម ប៉ែននុត និងព្រះអង្គម្ចាស់មុនីរ៉េត តំណាងប្រតិភូខ្មែរ។
- ថ្ងៃ ០៩ ឧសភា ១៩៥៣៖ បារាំងបានប្រគល់កងទ័ពផ្នែកអន្តរាគមន៍ឱ្យខ្មែរវិញ។
- ថ្ងៃ ១២ មិថុនា ១៩៥៣៖ នៅខេត្តសៀមរាប សម្តេច សីហនុ បានប្រកាសយ៉ាងឧឡារិកថាប្រជាជាតិខ្មែរទាំងមូលបានសម្តែងនូវទឹកចិត្តដ៏មោះមុតក្នុងការទាមទារឯករាជ្យពីបារាំង បានដាច់ខាតទោះបីជាបារាំងពុំមានឆន្ទៈក្នុងការប្រគល់ឯករាជ្យឲ្យយើងក៏ដោយ។

- ថ្ងៃ ២៩ សីហា ១៩៥៣៖ មានការចុះហត្ថលេខានៃការព្រមព្រៀងបារាំង-ខ្មែរ ផ្ទេរផ្នែកយុត្តិធម៌ និងប៉ូលីសមកឲ្យខ្មែរ។
- ថ្ងៃ ១៧ តុលា ១៩៥៣៖ បារាំងប្រគល់អធិបតេយ្យភាពផ្នែកយោធាកម្ពុជាទាំងមូល។
- ថ្ងៃ ០៩ វិច្ឆិកា ១៩៥៣៖ ប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញពីបារាំង។
- ថ្ងៃ ១៧-៣០ ធ្នូ ១៩៩៣៖ ប្រតិបត្តិការមហាសាមគ្គី បណ្តេញពួកវៀតមិញចេញពីកម្ពុជា។
- ថ្ងៃ ២៦ មេសា ១៩៥៤៖ សន្និសីទក្រុងសឺណែវដោយមានតំណាងប្រទេសចំនួន១៩ចូលរួម
- ថ្ងៃ ០១ សីហា ១៩៥៤៖ សៀមបានលើកទ័ពចូលកាន់កាប់លើទឹកដីប្រាសាទព្រះវិហារ។
- ការបោះឆ្នោតជាលើកដំបូងនៅកម្ពុជា ដើម្បីជ្រើសរើសសភាធម្មនុថ្ងៃ ០១ កញ្ញា ១៩៤៦៖ ញ្ញ ដែលមាន ៦៧ អាសនៈ។
- ថ្ងៃ ០៦ ឧសភា ១៩៤៧៖ សម្តេចនរោត្តម សីហនុ បានប្រទានឱ្យប្រើប្រាស់រដ្ឋធម្មនុញ្ញ។
- ថ្ងៃ ០៤ មិថុនា ១៩៤៩៖ បារាំងបានប្រគល់ទឹកដីកម្ពុជាក្រោម ទៅឱ្យស្តេចយួន បាវដាយ។
- ថ្ងៃ ០៨ វិច្ឆិកា ១៩៤៩៖ កិច្ចព្រមព្រៀងបារាំងខ្មែរ មានអត្ថន័យថា ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យមួយស្ថិតនៅក្នុងសហព័ន្ធឥណ្ឌូចិនបារាំង។
- ថ្ងៃ ១៥ មិថុនា ១៩៥២៖ សម្តេចនរោត្តម សីហនុ រំលាយរដ្ឋាភិបាល ហើយក្តាប់អំណាចដោយផ្ទាល់ និងសន្យាទាមទារឯករាជ្យពីបារាំងឱ្យបានក្នុងរយៈពេល៣ឆ្នាំ។
- ថ្ងៃ ០៩ កុម្ភៈ ១៩៥៣៖ សម្តេចនរោត្តម សីហនុ ទ្រង់យាងចេញទៅបំពេញរាជសកម្មភាពទាមទារឯករាជ្យនៅបារាំង។
- ថ្ងៃ ០៥ មីនា ឆ្នាំ ១៩៥៣ សម្តេចនរោត្តសីហនុ ផ្ញើលិខិតទៅលោកប្រធានាធិបតីបារាំងសង់អូរីយ៉ូល។
- ថ្ងៃ ១២ មេសា ១៩៥៣៖ នៅប្រទេសកាណាដា សម្តេច សីហនុ ទ្រង់បានធ្វើសន្និសីទកាសែតមួយតាមរយៈវិទ្យុកាណាដា។
- ថ្ងៃ ០១ មករា ១៨៨៧៖ ការស្តារឡើងវិញនូវប្រព័ន្ធរដ្ឋបាលខ្មែរ។
- ថ្ងៃ ០៣ តុលា ១៨៩៣៖ សន្ធិសញ្ញាបារាំង-សៀម ដោយសៀមសន្យាថា មិនប្រើកម្លាំងទ័ពលើទឹកដីខេត្តសៀមរាម បាត់ដំបង និងសេរីសោភ័ណ។
- ថ្ងៃ ១៥ ធ្នូ ១៨៩៤៖ សាលាបារាំងចុងបូព៌ាប្រទេសបង្កើតឡើង នៅទីក្រុងហាណូយ ក្រោមការផ្តួចផ្តើមរបស់លោក ប៉ូល ឌូមរ។
- ថ្ងៃ ១៣ កុម្ភៈ ១៩០៤៖ អនុញ្ញាបារាំង-សៀម ដោយសៀមបានប្រគល់មកឲ្យខ្មែរវិញនូវទឹកដីភាគខាងជើង ម្លូពស្ទឹងត្រែង ទន្លេរពៅ និងខេត្តកោះកុង។
- ថ្ងៃ ២៣ មីនា ១៩០៧៖ សន្ធិសញ្ញាបារាំង-សៀម ស្តីអំពីការប្រគល់ខេត្តបាត់ដំបងសៀមរាប សេរីសោភ័ណ្ឌមកឲ្យខ្មែរវិញ។
- ថ្ងៃ ៣១ មករា ១៩៣៩៖ បារាំងបានបញ្ចូលកោះត្រល់ទាំងមូលក្រោមការគ្រប់គ្រងរបស់អាជ្ញាធរដែនដីកូសាំងស៊ីន។

- ថ្ងៃ ២៤ តុលា១៩៤១៖ ព្រះសម្ដេចនរោត្តម សីហនុ រាជាភិសេកជាព្រះចៅក្រុងកម្ពុជាធិបតី
- ថ្ងៃ ១២ មីនា ១៩៤៥៖ សម្តេចនរោត្តម សីហនុ ប្រកាសឯករាជ្យ ហើយប្រកាសបដិសេធសន្ធិសញ្ញាបារាំង-ជប៉ុន-សៀម ចុះថ្ងៃទី ០៩ ឧសភា ១៩៤១។
- ថ្ងៃ ០៤ មករា ១៩៤៦៖ អនុសញ្ញាបារាំង-ខ្មែរ បានប្រគល់ស្វ័យភាពរដ្ឋបាលឱ្យកម្ពុជា។
- ថ្ងៃ ០១ កញ្ញា ១៨៥៨៖ បារាំងលើកទ័ពចូលអាល្លឺមដើម្បីជួយស្រោចស្រង់ជីវិតពួកអ្នកផ្សព្វផ្សាយសាសនាកាតូលិក ដែលនៅសេសសល់ពីការកាប់សំលាប់របស់ស្តេចអណ្ណាម។
- ថ្ងៃ ១៨ កុម្ភៈ ១៨៥៩៖ បារាំងចូលកាន់កាប់ក្រុងព្រៃនគរ និងតំបន់ជិតខាង។
- ថ្ងៃ ១៤ តុលា ១៨៦០៖ ព្រះអង្គឌួង ចូលទិវង្គតនៅរាជធានាឧដុង្គ។
- ថ្ងៃ ១១ សីហា ១៨៦៣៖ សន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរធ្វើឡើងដោយអគ្គទេសាភិបាលបារាំងប្រចាំកូសាំងស៊ីន ដឺឡាក្រង់ឌីយែរ និងមហាឧបរាជកម្ពុជាព្រះបាទនរោត្តម។
- ថ្ងៃ ០១ ធ្នូ ១៨៦៣៖ សន្ធិសញ្ញាសម្ងាត់ខ្មែរ-សៀម ដែលបានបញ្ជាក់ថា ខ្មែរនៅតែជារដ្ឋចំណុះរបស់សៀមដដែល។
- ថ្ងៃ ០៣ មិថុនា ១៨៦៤៖ ព្រះបាទនរោត្តម ធ្វើពិធីរាជាភិសេកជាព្រះចៅក្រុងកម្ពុជាធិបតី។
- ថ្ងៃ ១៥ កក្កដា ១៨៦៧៖ សន្ធិសញ្ញាបារាំង-សៀម ស្ដីអំពីការទទួលស្គាល់អាណាព្យាលបារាំងមកលើកម្ពុជា។
- ថ្ងៃ ១៥ មករា ១៨៧៧៖បារាំងបានឱ្យព្រះបាទនរោត្តមចេញញ្ញាតិកំណែទម្រង់សង្គមខ្មែរ។
- ថ្ងៃ ១៧ មិថុនា ១៨៨៤៖ អនុសញ្ញាបារាំងបានបង្ខំដកអំណាចចេញពីព្រះបាទនរោត្តម។

➢ សម្បត្តិវប្បធម៌ខ្មែរដែលបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

✍ ផ្នែករូបិយមានដូចជា:

- ប្រាសាទនៅតំបន់អង្គរ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩២ នៅទីក្រុងសាន់តាហ្វេ សហរដ្ឋអាមេរិច។
- ប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលកាលពី ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។
- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ នៅទីក្រុងប្រ៊ិចថោនប្រទេសបារបារដូស។
- ប្រាសាទសម្បូរព្រៃគុក ត្រូវបានដាក់បញ្ចូលកាលពី ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៧ នៅទីក្រុងក្រាកូវប្រទេសប៉ូឡូញ ។

✍ ផ្នែកអរូបិយមានដូចជា:

- របាំព្រះរាជទ្រព្យ ត្រូវបានដាក់បញ្ចូលកាលពី ថ្ងៃទី៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ នៅទីក្រុងអ៊ីស្តន់ប៊ុលប្រទេសតួគី។
- ល្ខោនស្រមោលស្បែកធំ ត្រូវបានដាក់បញ្ចូលកាលពី ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅទីក្រុងប៉ារីសប្រទេសបារាំង។

- រឿងរាមកេរ្តិ៍តាគ្រុឌ ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៤ នៅទីក្រុងក្វាងចូវប្រទេសចិន។
- ល្បែងទាញព្រ័ត្រ ត្រូវបានដាក់បញ្ចូលកាលពី ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ នៅទីក្រុងវិនហុក ប្រទេសណាមីប៊ី។
- ចាប៉ីដងវែង ត្រូវបានដាក់បញ្ចូលកាលពីថ្ងៃទី ៣០ ខែ វិច្ឆិការ ឆ្នាំ ២០១៦ នៅទីក្រុងអាឌីសអាបាបាប្រទេសអេត្យូពី។
- ល្ខោនខោល ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនាថ្ងៃទី ២៨ ខែ វិច្ឆិកាឆ្នាំ ២០១៨ នៅទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីស ។

✍ ប្រទេសធំជាងគេទាំង៥នៅលើពិភពលោក

១. រុស្ស៊ី (១៧,១ លាន គីឡូម៉ែត្រការ៉េ)

២.កាណាដា (៩,៩៨៤លាន គីឡូម៉ែត្រការ៉េ )

៣.សហរដ្ឋអាមេរិក (៩,៦៣លាន គីឡូម៉ែត្រការ៉េ)

៤.ប្រទេសចិន (៩,៦លាន គីឡូម៉ែត្រការ៉េ)

៥.ប្រេស៊ីល ( ៨,៥១ លានគីឡូម៉ែត្រការ៉េ)

✍ ប្រទេសតូចជាងគេនៅលើពិភពលោក

១. ប្រទេសវ៉ាទីកង់ (0.44 គីឡូម៉ែត្រការ៉េ)

២.ប្រទេសម៉ូណាកូ (2.02 គីឡូម៉ែតការ៉េ)

៣.ប្រទេសណូរុ (21 គីឡូម៉ែត្រការ៉េ)

៤.ប្រទេស Tuvalu (26 គីឡូម៉ែត្រការ៉េ)

៥.ប្រទេសសានម៉ារីណូ ( 61 គីឡូម៉ែត្រការ៉េ)

ទ្វីប អាស៊ី- Asiaមានផ្ទៃដី44,614,000 $Km^2$

- អាស៊ានបង្កើតឡើងនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៦៧។ អាស៊ានជាមហាអំណាចទី ០៧ ផ្នែកសេដ្ឋកិច្ច។

អាស៊ានបង្កើតឡើងដំបូងមាន ៥ ប្រទេសដូចជាៈ

ប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសភីលីពីន ប្រទេសសិង្ហបូរី ប្រទេសថៃ នៅទីក្រុងបាំងកកប្រទេសថៃ។ បារាំងបានកាត់ទឹកដីកម្ពុជាក្រោម(កូសាំងស៊ីន)ឲទៅអំណាចស្តេចបាវដាយវៀតណាមនៅថ្ងៃទី០៤ខែមិថុនាឆ្នាំ ១៩៤៩។